ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១២ លេខ ៤៧ សប្តាហ៍ទី ៤ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១២

រាជកិច្ច

ផ្សាយដោយ

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

p

p

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៩-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៦០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ទីប្រឹក្សា ជំនួយការ និង ភ្នាក់ងារជាតិជាប់កិច្ចសន្យា របស់ឯកឧត្ដមប្រធាន សមាជិក សមាជិកា ក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ១៧ រូប ៤៦១៦

១១-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៦១ ស្ដីពី ការតែងតាំងលោកជំទាវ **លឹម សំខឿរ** ជាជំនួយការ ឯកឧត្ដម **ញ៉ែម ថ្នាំឌី** ប្រធានគណៈកម្មការ សិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង អង្កេត និង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា នៃរដ្ឋសភា មានឋានៈស្មើអគ្គនាយក ៤៦១៧

១៣-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៦២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ អស់លោក លោកស្រី មន្ត្រីរាជការស៊ីវិលនៅរាជធានីភ្នំពេញ ចំនួន ៥៣ រូប ៤៦១៨

១៣-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៦៣ ស្ដីពី ការតម្លើងឋានៈស្មើ អគ្គនាយក ជូនឯកឧត្ដម **ខឿ អំណត់** ទីប្រឹក្សាអមក្រសួងសាធារណការ និង ដឹកជញ្ជូន ៤៦២០

១៣-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៦៤ ស្ដីពី ការតែងតាំងលោក **ផល សាមន** ជា ឧកញ៉ា ៤៦២១

១៣-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៦៥ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ជូនឯកឧត្ដម **មាស ស៊ឿន** ពីឋានន្តរស័ក្តិវរៈមន្ត្រីថ្នាក់លេខ ១ ទៅឋានន្តរស័ក្តិ ឧត្ដមមន្ត្រី ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសាធារណការ និង ដឹកជញ្ជូន ៤៦២២

១៣-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៦៦ ស្ដីពី ការប្ដូរប្រភេទក្របខ័ណ្ឌតាមមុខតំណែងជូនលោក **តែង ពៅ** ពីឋានន្តរស័ក្តិក្រមការដើមខ្សែ ថ្នាក់លេខ ១០ ទៅឋានន្តរស័ក្តិ អនុមន្ត្រីថ្នាក់លេខ ១៤ ជាករណីពិសេស នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសាធារណការ និង ដឹកជញ្ជូន ៤៦២៣

១៣-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៦៧ ស្ដីពី ការតែងតាំងឯកឧត្ដម **ឯត សុនចាន់** ជា អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ៤៦២៤

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១៥-៦-២០១២ -អនុក្រឹត្យលេខ ៩៤ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៤៦២៥
១៤-៦-២០១២ -អនុក្រឹត្យលេខ ៧០៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៤៦២៧
១៤-៦-២០១២ -អនុក្រឹត្យលេខ ៧០៧ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៤៦២៩
១៤-៦-២០១២ -អនុក្រឹត្យលេខ ៧០៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៦៣០
១៤-៦-២០១២ -អនុក្រឹត្យលេខ ៧០៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៦៣២
១៤-៦-២០១២ -អនុក្រឹត្យលេខ ៧១០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៦៣៣
១៤-៦-២០១២ -អនុក្រឹត្យលេខ ៧១១ អនក្រ.តត ស្តីពី ការកែសម្រួលភារកិច្ចមន្ត្រីរាជការ ៤៦៣៤
១៥-៦-២០១២ -អនុក្រឹត្យលេខ ៧១២ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ និង មេដាយការងារ ៤៦៣៥
១៥-៦-២០១២ -អនុក្រឹត្យលេខ ៧១៣ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៤៦៣៨

២. សេចក្តីសម្រេច

២៥-៦-២០១២ -សេចក្តីសម្រេចលេខ ២៤ សសរ ស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យការអនុវត្តនីនយោបាយចាស់ សកម្មភាពថ្មី លើវិស័យដីធ្លី ៤៦៣៩

III. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៩-៦-២០១២ -សេចក្តីជូនដំណឹងលេខ ៣៧៨៤ សហវ.អគរ ៤៦៤១

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៣-៥-២០១២ -ប្រកាសលេខ ៤៩៩ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គាងស៊ីណាន់ហ្វៃរ៉ូស មេថល គ្រុប (ខេមបូឌា) បង្កើតរោងចក្រ ផលិតដែកស្អិត (Pig Iron) ៤៧១៣
២៥-៥-២០១២ -ប្រកាសលេខ ៥០៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ុមី (ខេមបូឌា) វ៉ាយរីង ស៊ីស្ទឹម បង្កើតរោងចក្រ ផលិតខ្សែភ្លើងគ្រឿងអេឡិចត្រូនិច ៤៧១៧

៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

២១-៥-២០១២ -ប្រកាសលេខ ៣២៣ ប្រក.កសក ស្តីពី ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ ក្នុងខេត្តក្រចេះ ៤៧២១

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ទីប្រឹក្សា ជំនួយការ
និង ភ្នាក់ងារជាតិជាប់កិច្ចសន្យារបស់ឯកឧត្តមប្រធាន សមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ១៧ រូប
ដែលមានស្នាដៃល្អក្នុងការខិតខំបំពេញភារកិច្ចទទួលបានលទ្ធផលល្អប្រសើរ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :
១- ឯកឧត្តម **ម៉េង គឹមលី**

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :
១- លោកជំទាវ **ហួង ដារ៉ាវី**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :
១- លោកជំទាវ **ជួន ច័ន្ទទេវី**
២- ឯកឧត្តម **ឈួរ សេរីចេតនា**
៣- ឯកឧត្តម **ចាប ញ៉ាលីវុធ**

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :
១- ឯកឧត្តម **ផាត់ ពៅស៊ាង**
២- ឯកឧត្តម **ព្រហ្ម ចិចិត្រសុភា**
៣- ឯកឧត្តម **គង់ រ៉ាធី**
៤- ឯកឧត្តម **ជួន ចន្ទ្រាណា**
៥- ឯកឧត្តម **ឡៀម សម្ផស្ស**
៦- លោកស្រី **ឯក ម៉ាស៊ីច័ន្ទ**

ង- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** :
១- លោក **យ៉ន ពីទូ**

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :
១- ឯកឧត្តម **អេង សុត្ថាវុធ**
២- ឯកឧត្តម **ស៊ាន សុធាភារក្ស**
៣- ឯកឧត្តម **ធន់ ច័ន្ទធារ័ត្ន**
៤- កញ្ញា **ឡៀម គញ្ញូនា**
៥- លោក **ឈឹម ពេជ្រស្នួរ**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចាត. ១២០៦-៥៦៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១២

លេខ: ៤៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/កម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៤ នៃរដ្ឋសភា នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការជ្រើសតាំងថនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីសម្រេចលេខ ៤៧៦ រ.ស ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ របស់រដ្ឋសភា ស្តីពីរបបប្រាក់បំណាច់ ប្រាក់ធានារ៉ាប់រងសង្គម និងរបបបេសកកម្មរបស់តំណាងរាស្ត្រ
- បានទ្រង់យល់សេចក្តីសម្រេចរួមលេខ ០១ គ.រ.ក ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ស្ថាប័ននីតិប្បញ្ញត្តិ ស្តីពីរបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗ របស់មន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ .. ត្រូវបានតែងតាំងលោកជំទាវ **លឹម សាំខឿរ** ជាជំនួយការ ឯកឧត្តម **ញ៉ែម ថ្លាមី** ប្រធានគណៈកម្មការ សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា នៃរដ្ឋសភា មានឋានៈស្មើ **អគ្គនាយក**។

មាត្រា២ .. សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ។

មាត្រា៣ .. ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៧.១២០៦.៥៥៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២

លេខ: ៥៤៤ ច.ល
[illegible]
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៥២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

អស់លោក លោកស្រីមន្ត្រីរាជការស៊ីវិលនៅរាជធានីភ្នំពេញ ចំនួន ៥៣ រូប ដែលបានខិតខំប្រឹងប្រែង បំពេញភារកិច្ចបានល្អ មានស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

ដូច

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **ធិបឌិន្ទ** ៖

១-លោក **កេត ឆៃ**
២-លោក **អង ណាង**
៣-លោក **ប៉ិល កុសល**
៤-លោក **ឧក ពុធដារ៉ា**
៥-លោក **គួប ស្នេះ**
៦-លោក **ឈីម សុភា**
៧-លោក **សាំង សុភៈចមិត្រ**
៨-លោកស្រី **ព្រុំ រដ្ឋា**
៩-លោកស្រី **ជា សុគន្ធ**
១០-លោក **អ៊ូ ស៊ីផាណារិទ្ធ**
១១-លោក **ជីន ប៉ោ**
១២-លោក **ឈាង ច៉ាង**
១៣-លោក **ឈឹម ឌីណា**
១៤-លោក **ផែង សុខេម**
១៥-លោក **ឡុង ប៉ែត**

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **សេនា** ៖

១-លោកស្រី **សក់ ចិន្តារី**
២-លោក **ចេង មុនីរ៉ា**
៣-លោក **ព្រុំ សំខាន់**
៤-លោក **ហែម ដារិទ្ធិ**
៥-លោកស្រី **គម សេដ្ឋាលី**
៦-លោក **ស៊ិន បុណ្ណមី**
៧-លោក **ឌី ជូរី**
៨-លោក **សួរ ផាន់ណារ៉ា**
៩-លោកស្រី **ផេង រឿង**
១០-លោកស្រី **សួន ចាន់ណារី**
១១-លោកស្រី **កែច ច័ន្ទសុនណារី**
១២-លោក **អ៊ុក សាគល**
១៣-លោក **ចាត ស៊ីណាង**
១៤-លោក **ស៊ុំ ប៊ុនធឿន**

ROYAUME du CAMBODGE

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ៖

១-លោក ឈ្យុង ឌីម៉ង់
២-លោក ម៉ៅ គុលម៉ារឌី
៣-លោក ឆៀច សំអឿន
៤-លោកស្រី ឆាច ធមនីរ៉ា
៥-លោក អ៊ី សុខឡេង
៦-លោកស្រី ជា នីតា
៧-លោក ម៉ុច ម៉ានិត
៨-លោក ថេង សុផុល
៩-លោក ឡុយ ប៊ុនសេរីវឌ្ឍមុនី
១០-លោក អ៊ិត ជំនិត
១១-លោក អ៊ូ វ៉េន
១២-លោកស្រី កែច ដាវ
១៣-លោក សំ ស៊ីឈៀក
១៤-លោក ប៊ុន ដារ៉ា
១៥-លោក សែម ដារិទ្ធ
១៦-លោកស្រី ម៉ម សុធី
១៧-លោក សួន ផល្លី
១៨-លោក យូ រដ្ឋា
១៩-លោក ឯក យឿន
២០-លោក យឹម ឡូង
២១-លោកស្រី អែម ស៊ីនណារី
២២-លោក ឆាង សុផារី
២៣-លោក មុត ពិសី
២៤-លោក មួក ម៉ុរ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារ.១២០៦.៥៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១២

ប្រេខ: ៥៦៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរងនៃទីស្តីការគណៈរដ្ឋមន្ត្រី
សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានដំឡើងឋានៈស្មើ **អគ្គនាយក** ជូនឯកឧត្តម **ខៀវ អំណាត់** ទីប្រឹក្សាអមក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧. ១២០៦. ៥៦៩

លេខ: ៥៥៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១២
អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក ឆិល សាមន

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ជាអេ.១២០៦.៥៧០

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២

លេខៈ ៥៣៩០.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

ប្រការ ១៖ ត្រូវបានតម្លើងឋានន្តរស័ក្តិជូន ឯកឧត្តម **មាស សឿន** ពីឋានន្តរស័ក្តិ វរៈមន្ត្រីថ្នាក់លេខ ១ ទៅឋានន្តរស័ក្តិ **ឧត្តមមន្ត្រីថ្នាក់លេខ ៣** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសាធារណការ និងដឹកជញ្ជូន ។

ប្រការ ២៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

ប្រការ ៣៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៩.១២០៦.៥៣១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២

លេខ: ៥៤៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
ម៉ម ឃុន សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

ប្រការ ១៖ ត្រូវបានប្តូរប្រភេទក្របខ័ណ្ឌតាមមុខតំណែងជូន លោក **កែវ ពៅ** ពីឋានន្តរស័ក្តិក្រមការដើមខ្សែ ថ្នាក់លេខ ១០ ទៅឋានន្តរស័ក្តិ អនុមន្ត្រីថ្នាក់លេខ ១៤ ជាករណីពិសេស នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសាធារណការ និងដឹកជញ្ជូន ។

ប្រការ ២៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

ប្រការ ៣៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១២០៦.៥៧២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២

លេខៈ ៥៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦ /០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឯក សុខមាន់** ជាអនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

រ.ស.ដ. ១២០៦.៥៧៣

លេខៈ ៥៤០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើអនុបយោគ ជូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់ក្រសួងមហាផ្ទៃ
- តាមសំណើ របស់ក្រសួងសុខាភិបាល

សម្រេច

មាត្រា ១ :-

ត្រូវបានដាក់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំង៖

-អតីតផ្ទះសំណាក់សូវៀត ស្ថិតនៅផ្លូវលេខ២៧១ កែងផ្លូវលេខ១៨៧ ភូមិ២ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានផ្ទៃដីទំហំ ៣.១៥៣,៦៥ ម៉ែត្រក្រឡា។

-ទីតាំងដីទំនេរ០២កន្លែង របស់មន្ទីរសុខាភិបាល ខេត្តកំពង់ចាម ស្ថិតនៅតាមដងផ្លូវជាតិលេខ ៧ចាស់

p

ក្នុងភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម ដែលមានដីទំហំ ១.៨៤៦ ម៉ែត្រក្រឡា។
-ទីតាំងសាលាឃុំបុសខ្នុរ ស្ថិតនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ដែលមានដីទំហំ ២៨០ ម៉ែត្រក្រឡា។

មាត្រា ២ :-

ការលុបទីតាំងដូចមានចែងក្នុងមាត្រា ១ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីដោយក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល សាលាខេត្តកំពង់ចាម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ៣ :-

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ចាមត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៣៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៣៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកស្រីវរសេនីយ៍ទោ **ស្រី ចាន់** អត្តលេខ ០៣០៨៣

២- លោកស្រីវរសេនីយ៍ទោ **ឌី សុជាតិ** អត្តលេខ ០៨១០១

៣- លោកស្រីវរសេនីយ៍ទោ **ឆ្លាន់ សុផល** អត្តលេខ ០៨១៨៤

៤- លោកស្រីវរសេនីយ៍ទោ **គុជ ឡោនី** អត្តលេខ ០៨៥៨៨

៥- លោកស្រីវរសេនីយ៍ទោ **យូ ម៉ូលីមុន** អត្តលេខ ១២១៩៤ ។

p

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧០ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សម្រេច

មាត្រា ១ .—

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជន ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធនានា នៅវត្តមុនីមានជ័យ (ហៅវត្តប្រក់ក្តារ) ស្ថិតនៅក្នុងឃុំវិហារលួង ស្រុកពញាឮ ខេត្តកណ្តាល ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

ក. មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០៣ គ្រឿង ប្រគេន និងផ្តល់ជូន :

១-ព្រះតេជគុណ **សៀន សំណាង** ព្រះចៅអធិការវត្តប្រក់ក្តារ

២-លោកជំទាវ **តុប សុភាព័រយ៍**

៣-លោកជំទាវ **ធាន ស្រីមុំ**

ខ. មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ០៣ គ្រឿង ផ្តល់ជូន :

១-លោក **កែវ ម៉ាន់ភាព**

២-លោក **សាន់ ចាន់សៀន**

៣-លោក **ចាន់ យុទ**

មាត្រា ២ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥៧៨...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន ១២ រូប ដែលបានលះបង់កំលាំង កាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធនានា នៅ**វត្តមុនីមានជ័យ** (ហៅវត្តប្រក់ក្អារ) ស្ថិតនៅក្នុងឃុំវិហារលួង ស្រុកពញាឮ ខេត្តកណ្តាល ដែលមានរាយនាមដូចខាងក្រោម :

ក. មេដាយមាសការងារចំនួន ០៥ គ្រឿង ផ្តល់ជូន :

១-លោកអាចារ្យ **ធិត្យ អ៊ុន**

២-លោកអាចារ្យ **អ៊ុន អូន**

៣-លោកអាចារ្យ **ខោល អ៊ិត**

៤-លោកអាចារ្យ **នុន ខន់**

៥-ឧបាសិកា **ជួន គីមសាយ**

ខ. មេដាយប្រាក់ការងារចំនួន ០៣ គ្រឿង ផ្តល់ជូន :

១-លោក **ឡុង រិន**

២-លោក **ខ៊ិត ផាន**

៣-លោក **ជុំ រស់**

p

គ~ មេដាយសេរីវឌ្ឍនការងារចំនួន ០៤ គ្រឿង ផ្តល់ជូន :

១-លោក អ៊ឹម ខាត់

២-លោក ម៉ៅ ហឿន

៣-លោក យ៉េត សុខា

៤-លោក សេ ហួយ

មាត្រា ២ .–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៧ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ កុដិ ឧបដ្ឋានសាលា ក្លោងទ្វារ និងសាលារៀន នៅ**វត្តបាយ៉ាប** ស្ថិតនៅក្នុងឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-ព្រះតេជគុណ	**ទ៉ា ទាសនា**	ព្រះចៅអធិការវត្តបាយ៉ាប	បច្ច័យចំនួន ១០.០៥០ ដុល្លារ
២-លោកស្រី	**យុគ ចិន្តា**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១១.០៥០ ដុល្លារ
៣-លោកស្រី	**ខឹម ផល្លី**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១០.១២០ ដុល្លារ
៤-លោក	**ព្រាប កែន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១០.០៥០ ដុល្លារ
៥-លោកស្រី	**យុគ ចរិយា**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១០.០៣០ ដុល្លារ
៦-ឧបាសិកា	**យុខ គីមស៊ុន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១០.០៣០ ដុល្លារ
៧-លោក	**សេ ឌី**	សប្បុរសជននៅខេត្តស្វាយរៀង	ថវិកាចំនួន ១០.០២០ ដុល្លារ

មាត្រា ២.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តស្វាយរៀង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១០ . អនក្រ . តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៨អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ចាន់ សុផល** ជាទីប្រឹក្សាក្រសួងសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ **អគ្គនាយករង** ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១២

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

គណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១១ . អនក្រ . បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
  បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៨អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា ១ : ត្រូវបានកែសម្រួលភារកិច្ច លោក **គឹម សាន់** ពីអគ្គនាយករងរដ្ឋបាល មកជាប្រធាន **នាយកដ្ឋានបុគ្គលិក-ធនធានមនុស្ស** នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០១២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ និង មេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** និង **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម ចំនួន ៤៨ រូប ដែលមានស្នាដៃក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

ក-គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ **ធិបឌិន្ទ** ជូន:

១-លោក	**គង់ សោភ័ណ្ឌរត្ន**	អភិបាលស្រុកជើងព្រៃ	
២-លោក	**ស៊ូ ម៉ៃ**	ប្រធានក្រុមប្រឹក្សាស្រុកជើងព្រៃ	
៣-លោកវរសេនីយ៍ត្រី	**ហេង ធុទ្ធី**	អត្តលេខ១១៤២៦	អធិការនគរបាលស្រុកជើងព្រៃ

ខ-មេដាយមាសការងារ ជូន:

១-លោកអនុសេនីយ៍ឯក	**យ៉េម សុផល**	អត្តលេខ០៤១១៥	អធិការរងនគរបាលស្រុកជើងព្រៃ
២-លោកអនុសេនីយ៍ឯក	**ប្រាក់ សុគុណា**	អត្តលេខ១៥៤០២	អធិការរងនគរបាលស្រុកជើងព្រៃ
៣-លោកអនុសេនីយ៍ឯក	**អ៊ិម ហ៊ី**	អត្តលេខ០៨៨៤២	អធិការរងនគរបាលស្រុកជើងព្រៃ
៤-លោកអនុសេនីយ៍ឯក	**ប្រាក់ សុខឡឿន**	អត្តលេខ០៤១១៥	អធិការរងនគរបាលស្រុកជើងព្រៃ

៥-លោកអនុសេនីយ៍ឯក	**ជិន មីន**	អត្តលេខ០៨១០៨	អធិការរងនគរបាលស្រុកជើងព្រៃ
៦-លោកអនុសេនីយ៍ឯក	**ស៊ុយ សំអាត**	អត្តលេខ០២០៨៣៨	មេបញ្ជាការកងរាជអាវុធហត្ថស្រុក
៧-លោកអនុសេនីយ៍ឯក	**សែម ហាក់**	អត្តលេខ១៩៥៩៥៨	ជំនួយការកងរាជអាវុធហត្ថខេត្ត
៨-លោកអនុសេនីយ៍ទោ	**ឈាន ឈាត**	អត្តលេខ១៩២៣៨	នាយប៉ុស្តិ៍នគរបាលរដ្ឋបាលសំពងជ័យ
៩-លោកអនុសេនីយ៍ទោ	**ផុន សុខុម**	អត្តលេខ១៥៥០១	នាយប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃចារ
១០-លោកអនុសេនីយ៍ទោ	**ស៊ី សេន**	អត្តលេខ១៥៥០៦	នាយប៉ុស្តិ៍នគរបាលរដ្ឋបាលគោករវៀង
១១-លោកអនុសេនីយ៍ទោ	**ពេជ្រ ឃ៉ុខ**	អត្តលេខ១៥៥០៣	នាយប៉ុស្តិ៍នគរបាលរដ្ឋបាលសូទិព្វ
១២-លោកអនុសេនីយ៍ទោ	**សេក សំរឿន**	អត្តលេខ១៥៥០៥	នាយប៉ុស្តិ៍នគរបាលរដ្ឋបាលខ្នារដំបង
១៣-លោកអនុសេនីយ៍ទោ	**សេខ សាន**	អត្តលេខ១៥៥០៤	នាយប៉ុស្តិ៍នគរបាលរដ្ឋបាលផ្តៅជុំ
១៤-លោកអនុសេនីយ៍ទោ	**គីម ស្រ៊ុន**	អត្តលេខ១៥៥១១	នាយប៉ុស្តិ៍នគរបាលរដ្ឋបាលព្រីងជ្រុំ
១៥-លោកអនុសេនីយ៍ទោ	**ជាង សែ**	អត្តលេខ១៥៤០៤	នាយប៉ុស្តិ៍នគរបាលរដ្ឋបាលស្រម៉រ
១៦-លោកអនុសេនីយ៍ទោ	**ឡាញ់ លាង**	អត្តលេខ១៩២៣០	នាយប៉ុស្តិ៍នគរបាលរដ្ឋបាលស្ទឹងជ័យ
១៧-លោកអនុសេនីយ៍ទោ	**យ៉ាង ផែ**	អត្តលេខ១៩២៣៤	នាយប៉ុស្តិ៍នគរបាលរដ្ឋបាលត្រពាំងគរ
១៨-លោកអនុសេនីយ៍ទោ	**ឯល តា**	អត្តលេខ១៥៤០៥	នាយផ្នែកសណ្តាប់ធ្នាប់នគរបាលស្រុក
១៩-លោកអនុសេនីយ៍ទោ	**លី រ៉ែត**	អត្តលេខ១៥៤៩៩	នាយផ្នែកសន្តិសុខនគរបាលស្រុក
២០-លោកអនុសេនីយ៍ទោ	**រឿន សេងលាង**	អត្តលេខ១៩៣២២	នាយផ្នែកព្រហ្មទណ្ឌនគរបាលស្រុក
២១-លោកអនុសេនីយ៍ទោ	**កែវ ចន្ទារិទ្ធ**	អត្តលេខ១៥៤០៦	នាយផ្នែកស្ថិតិ-អត្តសញ្ញាណប័ណ្ណ
២២-លោកអនុសេនីយ៍ត្រី	**ជឹម សុផល**	អត្តលេខ២៤៧២៣	នាយផ្នែកបច្ចេកទេសនគរបាលស្រុក
២៣-លោកអនុសេនីយ៍ត្រី	**ឈុន សុផារិទ្ធ**	អត្តលេខ៤៧១១០	នាយផ្នែកសេនាធិការនគរបាលស្រុក
២៤-លោកអនុសេនីយ៍ត្រី	**ហេង សុផាត**	អត្តលេខ៦២៥៧៤	នាយរងផ្នែកស្ថិតិ-អត្តសញ្ញាណប័ណ្ណ
២៥-លោកព្រិន្ទបាលឯក	**ស៊ីន ពិសី**	អត្តលេខ៥៩១០៥	មន្ត្រីផ្នែកសេនាធិការនគរបាលស្រុក
២៦-លោកព្រិន្ទបាលឯក	**ហ៊ុយ ម៉ុនផល**	អត្តលេខ៤៧១២១	មន្ត្រីផ្នែកសេនាធិការនគរបាលស្រុក

គ-មេដាយប្រាក់ការងារ ជូនៈ

១-លោកអនុសេនីយ៍	**ពេញ សារ៉េន**	អត្តលេខ៤៧៨៦៦	នាយរងផ្នែកបច្ចេកទេសនគរបាលស្រុក
២-លោកអនុសេនីយ៍ត្រី	**ជុំ សុវណ្ណ**	អត្តលេខ១៩២៣០	នាយរងផ្នែកសន្តិសុខនគរបាលស្រុក
៣-លោកអនុសេនីយ៍ត្រី	**ខែត ស៊ីដេត**	អត្តលេខ១៩២២១	នាយរងផ្នែកសណ្តាប់ធ្នាប់
៤-លោកព្រិន្ទបាលទោ	**ស៊ឹម សុំ**	អត្តលេខ៤៧០៩៦	នាយរងផ្នែកព្រហ្មទណ្ឌ
៥-លោកអនុសេនីយ៍ត្រី	**ម៉ៅ សម្បត្តិ**	អត្តលេខ១៩២៣៣	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលត្រពាំងគរ
៦-លោកអនុសេនីយ៍ត្រី	**ចាប ចន្ថា**	អត្តលេខ៤៧៨៦៤	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលត្រពាំងគរ
៧-លោកអនុសេនីយ៍ត្រី	**ម៉ៃ ឃុយ**	អត្តលេខ១៩២២៤	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលព្រៃចារ
៨-លោកអនុសេនីយ៍ត្រី	**ឆៃ គឹមឈុន**	អត្តលេខ១៩២២៥	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលសូទិព្វ
៩-លោកអនុសេនីយ៍ត្រី	**សៀង សុធី**	អត្តលេខ១៩២២៦	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលសូទិព្វ
១០-លោកអនុសេនីយ៍ត្រី	**កៅ គឹមយន**	អត្តលេខ១៩២៣៥	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលព្រីងជ្រុំ
១១-លោកអនុសេនីយ៍ត្រី	**ជា ថៃសាន**	អត្តលេខ១៩២៣២	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលស្ទឹងជ័យ
១២-លោកអនុសេនីយ៍ត្រី	**ឡឹង ចូរ៉ែ**	អត្តលេខ១៩២៣១	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលស្ទឹងជ័យ
១៣-លោកព្រិន្ទបាលឯក	**ស៊ីន សារ៉េត**	អត្តលេខ៤៧១២៤	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលសំពងជ័យ
១៤-លោកព្រិន្ទបាលទោ	**ឈឹម តុង**	អត្តលេខ៦៥៥៩៧	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលសំពងជ័យ
១៥-លោកព្រិន្ទបាលឯក	**ហេង សុផាន់**	អត្តលេខ៤៧១០៤	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលស្រម៉រ
១៦-លោកព្រិន្ទបាលឯក	**ឃុន ខេមរ៉ាត**	អត្តលេខ៤៧១២៤	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលសំពងជ័យ
១៧-លោកព្រិន្ទបាលទោ	**ឡូ ហឿន**	អត្តលេខ៤៧៨៨៧	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលខ្នារដំបង
១៨-លោកពលបាលឯក	**ម៉ែន រ៉ាទី**	អត្តលេខ៤៧៨៥៣	នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលគោករវៀង

១៩-លោកពលបាលឯក **ជា សុផារី** អត្តលេខ៤៧៨៤៥ មន្ត្រីផ្នែកសណ្តាប់ធ្នាប់នគរបាលស្រុក

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការព្រឹទ្ធសភា
- -អគ្គលេខាធិការរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៦៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច.

មាត្រា ១..

ត្រូវបានបំពាក់**មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូននាយទាហានយោធភូមិភាគទី៧ នៃកងទ័ពប្រជាជនវៀតណាម ដែលមានស្នាដៃល្អក្នុងការជួយបង្ហាត់បង្រៀនដល់សិក្ខាកាមវគ្គហ្វឹកហ្វឺនទ័ពព្រៃរបស់យោធភូមិភាគទី៤ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-អនុសេនីយ៍ឯក **ផាម វ៉ាន់ហាំង** PAM VAN HANG មេបញ្ជាការរងវរសេនាតូចលេខ ៤៧

២-អនុសេនីយ៍ឯក **ង្វៀន វ៉ាន់លីវ** NGVIENG VAN LIV មេបញ្ជាការកងអនុសេនាធំលេខ ១ វរសេនាតូចលេខ៤៧

៣-អនុសេនីយ៍ទោ **ម៉ាយ ស៊ុនហ៊ុង** MAY SUN HUNG មេបញ្ជាការរងកងអនុសេនាធំលេ១ វរសេនាតូចលេខ៤៧

៤-អនុសេនីយ៍ទោ **ទ្រិន អាឃ្លាល់** TRIN AGHAL មេបញ្ជាការខ.១ កងអនុសេនាធំលេខ១ វរសេនាតូចលេខ ៤៧

៥-អនុសេនីយ៍ត្រី **លីវ វ៉ាន់យឿង** LIV VAN YUOENG មេបញ្ជាការខ.២ កងអនុសេនាធំលេខ១ វរសេនាតូចលេខ ៤៧

មាត្រា ២..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤ សសរ

សេចក្តីសំរេច

ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យការអនុវត្តន៍នយោបាយចាស់សកម្មភាពថ្មី លើវិស័យដីធ្លី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សា-គោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការត្រួតពិនិត្យការអនុវត្តន៍នយោបាយចាស់ សកម្មភាពថ្មី លើវិស័យដីធ្លី ។

ប្រការ ២ : គណៈកម្មការនេះមានសមាសភាព :

១- ឯកឧត្តម **អ៊ឹម ឈុនលឹម**	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន
២- ឯកឧត្តម **អ៊ុក រ៉ាប៊ុន**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក
៣- ឯកឧត្តម **ប្រាក់ សុខុន**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក
៤- ឯកឧត្តម **ឆាន់ សាផាន់**	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក

p

៥- ឯកឧត្តម **រ័ត្ន សារិន** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយ៍កម្ម និងសំណង់
ជាសមាជិក

៦- ឯកឧត្តម **អ៊ិត ណារី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ជាសមាជិក

៧- ឯកឧត្តម **ឆេង គីមស៊ុន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ជាសមាជិក

៨- ឯកឧត្តម **ចាយ សាមិត្ត** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន
ជាសមាជិក

៩- ឯកឧត្តម **សរ សុវណ្ណា** អគ្គនាយកសុរិយោដីនិងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ជាសមាជិក

ប្រការ ៣ : - គណៈកម្មការនេះមានភារកិច្ច :

- ត្រួតពិនិត្យ និងផ្តល់មតិជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសុំការសំរេចលើសំណើសុំកាត់ដីចេញពីព្រៃសម្បទាន ដីសម្បទានសេដ្ឋកិច្ច និងដីរដ្ឋ ដើម្បីចែកជូនប្រជាពលរដ្ឋកាន់កាប់ស្របច្បាប់ ។
- អនុវត្តនូវភារកិច្ចដទៃទៀតដែលរាជរដ្ឋាភិបាលប្រគល់អោយ ។

ប្រការ ៤ : ប្រធានគណៈកម្មការនេះមានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាជំនួយការក្នុងការអនុវត្តន៍ភារកិច្ចខាងលើ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
  រាជកិច្ច
- *ឯកសារ-កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣២៥៤ សហវ.ករ

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០១២

ជម្រាបជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា

កម្មវត្ថុ៖ ការធ្វើបច្ចុប្បន្នភាពឧបសម្ព័ន្ធ១នៃអនុក្រឹត្យ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ តាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ានឆ្នាំ២០០៧ (AHTN 2007) ឱ្យសុខដុមជាមួយ AHTN 2012 វិញ ដោយរក្សាខ្លឹមសារដើមទាំងស្រុងនៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងការហាមឃាត់ និងការដាក់កម្រិតកំណត់លើទំនិញនាំចេញ- នាំចូលជាធរមាន។

យោង៖
- អនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់។
- ចំណារដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២ លើលិខិតលេខ៣២៩៩ សហវ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ប្រកាសលេខ២៨១ សហវ.ប្រក.អគរ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០១២។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា មេត្តាជ្រាបថា ឧបសម្ព័ន្ធ១នៃអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ដូចយោងខាងលើ ត្រូវបានធ្វើបច្ចុប្បន្នភាព ដូចមានចែងក្នុងបញ្ជីជូនភ្ជាប់មកជាមួយលិខិតនេះ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា មេត្តាចាត់ចែងផ្សព្វផ្សាយ និងអនុវត្តតាមខ្លឹមសារនេះចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ តទៅ ឱ្យមានប្រសិទ្ធភាពតាមការគួរ ដោយអនុគ្រោះ។

សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា ទទួលនូវគារវកិច្ចពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីជូនជ្រាប និងសុំកិច្ចសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone: 855-23-724 664 Fax: 855-23-427 798

ឧបសម្ព័ន្ធនៃលិខិតលេខ៣៧៨៤ សហវ.ពគ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១២
បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ដែលស៊ីចង្វាក់ជាមួយ AHTN 2102

ល.រ	លេខកូដ	បរិយាយ	ប្រភេទលិខិតអនុញ្ញាតចេញដោយ												
			MIME	MOH	MOC	MAFF	NBC	MOE	MOI	CDC	MEF	MOCFA	MPTC	MOD	Other
1	0101.21.00	--សេះពូជសុទ្ធ				(2) (3) (7)									
2	0101.29.00	--ផ្សេងទៀត				(2) (3) (7)									
